## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តកណ្ដាល**

សំណុំរឿងព្រហ្មទណ្ឌលេខ ៨៩០ អក
ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៧
សាលក្រមព្រហ្មទណ្ឌលេខ ១៣១ "ណ"
ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២១

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តកណ្ដាល

បានបើកសវនាការជាសាធារណៈនាថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២១ ដែលមានសមាសភាពដូចខាងក្រោម៖

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ចៅក្រមជំនុំជម្រះ

**តំណាងអយ្យការ**

លោកស្រី [redacted] ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងខេត្តកណ្ដាល

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted] ក្រឡាបញ្ជី នៃសាលាដំបូងខេត្តកណ្ដាល

**ដើម្បីជំនុំជម្រះ**

លើសំណុំរឿងព្រហ្មទណ្ឌលេខ ៨៩០ អ.ក ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៧ ដែលមានជនជាប់ចោទឈ្មោះ [redacted] អើសស្នាក់ ភេទស្រី អាយុ៣៧ឆ្នាំ ជនជាតិអ៊ីស្លាម មុខរបរលក់ដូរ មានទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ននៅភូ[redacted] ខេត្តកណ្ដាល ឪពុកឈ្មោះ [redacted] ម៉ាត់ (ស្លាប់) ម្ដាយឈ្មោះ [redacted] ម៉ៃស៊ុំ (ស្លាប់) ប្ដីឈ្មោះ [redacted] អ៊ីសា ជានិតិជន ទោសពីមុនគ្មាន ។

ជាប់ចោទពីបទៈ **រំលោភលើទំនុកចិត្ត** ប្រព្រឹត្តនៅភូមិព្រែកតាពៅ សង្កាត់ដើមមៀន ក្រុងតាខ្មៅ ខេត្តកណ្ដាល កាលពីឆ្នាំ២០១៥ តាមបញ្ញត្តិមាត្រា ៣៩១ និងមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ ។

-ដែលមេធាវីឈ្មោះ [redacted] ការពារសិទ្ធិឱ្យជនជាប់ចោទ [redacted] អើសស្នាក់។

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុខមុនីនាថ ភេទស្រី មានទីលំនៅបច្ចុប្បន្ននៅផ្ទះលេខ២៣៨ ផ្លូវ ២១៧ ភូមិ៥ សង្កាត់អូឬស្សី២ ខណ្ឌ៧មករា រាជធានីភ្នំពេញ ។

**ការប្រព្រឹត្តរបស់ជនជាប់ចោទខាងលើមានដូចតទៅ៖**

កាលពីអំឡុងឆ្នាំ២០១៥ ឈ្មោះ [redacted] អើស្នាក់ ភេទស្រី អាយុ៣៧ឆ្នាំ បានទៅទិញឥវ៉ាន់ចាប់ហួយពីឈ្មោះ [redacted] សុខមុនីនាថ ភេទស្រី ចំនួន០៤ដង ដោយលើកទី១ ជនជាប់ចោទបានឱ្យលុយគ្រប់ ហើយលើកទី២ លើកទី៣ និងលើកទី៤ សរុបទឹកប្រាក់ចំនួន ២២,៣៤២ (បីម៉ឺនពីរពាន់បីរយសែសិបពីរ) ដុល្លាអាមេរិក ហើយឈ្មោះ [redacted] អើសស្នាក់ បានសងឱ្យទៅឈ្មោះ [redacted] សុខមុនីនាថ បានចំនួន ៨,៣០៧ (ប្រាំបីពាន់បីរយប្រាំពីរ) ដុល្លាអាមេរិក [redacted] អើសស្នាក់ មិនព្រមសងទៅឈ្មោះ [redacted] សុខមុនីនាថ ហើយនៅខ្វះប្រាក់

ចំនួន ១៤,០៣៥ (មួយម៉ឺនបួនពាន់សាមសិបប្រាំ) ដុល្លាអាមេរិក ពិតប្រាកដមែន ដោយឥវ៉ាន់ចាប់ហួយទាំងនោះគឺ [redacted] សុខមុនីនាថ ជាអ្នកយកមកឱ្យឈ្មោះ [redacted] អើសស្នាក់ ដល់ផ្ទះ ។

-បានឃើញ ដីកាបញ្ជូនរឿងឱ្យស៊ើបសួរលេខ ៧៣៥ ដកសស ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៧ របស់តំណាងអយ្យការសាលាដំបូងខេត្តកណ្ដាល ។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ៤២៩ ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្ដាល ។

-បានឃើញ ដីកាដំណោះស្រាយលេខ ៥៧២ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្ដាល ។

-បានឃើញ ដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខ ៩០៨ ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០២១ របស់ប្រធានសាលាដំបូងខេត្តកណ្ដាល ។

**នាពេលសវនាការ**

១- ជនជាប់ចោទឈ្មោះ [redacted] អើសស្នាក់ ភេទស្រី បានឆ្លើយថា៖ កាលពីអំឡុងឆ្នាំ២០១៥ ខ្លួនបានទៅទិញឥវ៉ាន់ចាប់ហួយពីឈ្មោះ [redacted] សុខមុនីនាថ ចំនួនបួនដង ដោយសរុបទាំងបួនលើកនេះ ខ្លួនបានជំពាក់ប្រាក់សរុបចំនួន ២២,៣៤២ ដុល្លាអាមេរិក ប៉ុន្តែខ្លួនបានសងទៅឱ្យឈ្មោះ [redacted] សុខមុនីនាថ ចំនួន ៨,៣០៧ ដុល្លាអាមេរិក ហើយនៅខ្វះចំនួន ១៤,០៣៥ ដុល្លាអាមេរិកទៀតទេ ។ មូលហេតុដែលខ្លួនមិនសងព្រោះខ្លួនរកស៊ីខាត ណាមួយប្ដីរបស់ខ្លួនបានចាកចោលផ្ទះ ដោយខ្លួនត្រូវចិញ្ចឹមកូន ។ ខ្លួនទទួលស្គាល់នូវប្រាក់ដែលបានជំពាក់ឈ្មោះ [redacted] សុខមុនីនាថ ចំនួន ១៤,០៣៥ ដុល្លាអាមេរិកទៀត ប៉ុន្តែខ្លួនសុំសងឱ្យគាត់ក្នុងមួយខែ ១០០ ដុល្លាអាមេរិក រហូតដល់សងបំណុលរួច ហើយបើសិនខ្លួនមានលទ្ធភាពលើសនេះ ខ្លួននឹងសងឱ្យឈ្មោះ [redacted] សុខមុនីនាថ បន្ថែមទៀត ។

២- អំណានចម្លើយដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុខមុនីនាថ ភេទស្រី បានឆ្លើយថា៖ កាលពីអំឡុងឆ្នាំ ២០១៥ ម៉ូយឥវ៉ាន់របស់ខ្លួនឈ្មោះ ស៊ីណា បាននាំម្ដាយមីងរបស់គាត់ឈ្មោះ [redacted] អើសស្នាក់ មកទិញឥវ៉ាន់ ចាប់ហួយរបស់ខ្លួនលើកទី១ ឈ្មោះ [redacted] អើសស្នាក់ បានអោយលុយគ្រប់ តែដល់លើកទី២ ទី៣ និងទី៤ សរុបទឹកប្រាក់ចំនួន ២២,៣៤២ ដុល្លាអាមេរិក ហើយឈ្មោះ [redacted] អើសស្នាក់ នេះបានសងតែ ៨,៣០៧ ដុល្លាអាមេរិក នៅខ្វះចំនួន ១៤,០៣៥ ដុល្លាអាមេរិក ដូចបានរៀបរាប់ក្នុងកំណត់ហេតុនៅនគរបាលយុត្តិធម៌ ។ នៅក្នុងរឿងនេះខ្ញុំមានសាក្សីពីរនាក់ឈ្មោះ [redacted] ធិរាជ ភេទប្រុស និងឈ្មោះ [redacted] ស៊ាមហូ ភេទប្រុស ។

៣- អំណានចម្លើយសាក្សីឈ្មោះ [redacted] ធិរាជ បានឆ្លើយថា៖ នៅថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៥ វេលាម៉ោងប្រាំមួយល្ងាច ថៅកែខ្លួនឈ្មោះ [redacted] សុខមុនីនាថ ភេទស្រី អាយុ២២ឆ្នាំ នៅសង្កាត់ផ្សារអូឬស្សី បានឱ្យខ្លួនបើកឡានដឹក ឥវ៉ាន់ចាប់ហួយមានច្រើនមុខ ចម្រុះយកទៅឱ្យឈ្មោះ [redacted] អើសស្នាក់ ភេទស្រីអាយុ៣៦ឆ្នាំ និងប្ដីឈ្មោះ [redacted] អ៊ីសា ភេទប្រុស អាយុ៤៣ឆ្នាំ អ្នកទាំងពីររស់នៅភូមិព្រែកតាកោ១ សង្កាត់ដើមមៀន ក្រុងតាខ្មៅ ខេត្តកណ្ដាល ដែលគាត់ទិញពីថៅកែរបស់ខ្លួន យកទៅលក់បន្ត ហើយខ្លួនបានដឹកឥវ៉ាន់ចាប់ហួយទៅឱ្យឈ្មោះ [redacted] អើសស្នាក់ នេះបានចំនួន ០៤ លើក ។

៤- អំណានចម្លើយសាក្សីឈ្មោះ [redacted] ស៊ាងហាយ បានឆ្លើយថា៖ នៅថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៥ វេលាម៉ោងប្រាំមួយល្ងាច ថៅកែខ្លួនឈ្មោះ [redacted] សុខមុនីនាថ ភេទស្រី បានឱ្យខ្លួនដឹកឥវ៉ាន់ទៅឱ្យឈ្មោះ [redacted]



Scanned with CamScanner

[redacted] អើសស្នាក់ ដល់ផ្ទះដែលមានទីតាំងនៅភូមិព្រែកតាពៅ១ សង្កាត់ដើមមៀន ក្រុងតាខ្មៅ ខេត្តកណ្ដាល ហើយខ្លួនបានដឹងបានចំនួនបីលើកតែប៉ុណ្ណោះ ។

៥- លោកមេធាវី [redacted] បានធ្វើសេចក្តីសន្និដ្ឋានថា៖ តាមចម្លើយជនជាប់ចោទ តាមចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី បង្ហាញឱ្យឃើញថា កូនក្តីរបស់ខ្លួនឈ្មោះ [redacted] អើសស្នាក់ ពិតជាបានទិញឥវ៉ាន់ចាប់ហួយពីឈ្មោះ [redacted] សុខមុនីនាថ ប្រាកដមែន ប៉ុន្តែដោយសារតែមានកូនក្តីខ្លួនរកស៊ីខាតទើបធ្វើឱ្យពុំមានលទ្ធភាពក្នុងការសងប្រាក់ទៅឱ្យដើមបណ្ដឹងរដ្ឋប្បវេណី ដែលសកម្មភាពនេះមិនមែនបទល្មើសព្រហ្មទណ្ឌឡើយ ស្នើសុំឱ្យតុលាការឱ្យកូនក្តីខ្លួនបានរួចផុតពីការចោទប្រកាន់ផង ។

៦- តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា៖ តាមចម្លើយជនជាប់ចោទ អំណានដើមបណ្ដឹងរដ្ឋប្បវេណី អំណានចម្លើយសាក្សី ព្រមទាំងភស្តុតាងនានា បង្ហាញឱ្យឃើញថាមានពិរុទ្ធភាពគ្រប់គ្រាន់ក្នុងការចោទប្រកាន់ទៅលើជនជាប់ចោទឈ្មោះ [redacted] អើសស្នាក់ ភេទស្រី ពីបទៈ រំលោភលើទំនុកចិត្ត ប្រព្រឹត្តនៅភូមិព្រែកតាពៅ សង្កាត់ដើមមៀន ក្រុងតាខ្មៅ ខេត្តកណ្ដាល កាលពីឆ្នាំ២០១៥ តាមបញ្ញត្តិមាត្រា ៣៩១ និងមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ ហេតុដូច្នេះស្នើសុំឱ្យតុលាការធ្វើការផ្តន្ទាទោសលើជនជាប់ចោទតាមកំណត់ច្បាប់។

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់អំណានចម្លើយសាក្សី

-ក្រោយពីបានស្តាប់សេក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានថយទៅពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

**យល់ឃើញថា**

**ក/ អំពីពិរុទ្ធភាព**

១- តាមដីកាដំណោះស្រាយលេខ ៥៧២ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្ដាល ឃើញថា ជនជាប់ចោទឈ្មោះ [redacted] អើសស្នាក់ ពិតជាបានជាប់ចោទពីបទៈ រំលោភលើទំនុកចិត្ត ប្រព្រឹត្តនៅភូមិព្រែកតាពៅ សង្កាត់ដើមមៀន ក្រុងតាខ្មៅ ខេត្តកណ្ដាល តាមបញ្ញត្តិមាត្រា ៣៩១ និងមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ ប្រាកដមែន។

២- តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] អើសស្នាក់ បង្ហាញឱ្យឃើញថា៖ ខ្លួនពិតជាបានទិញឥវ៉ាន់ចាប់ហួយពីដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុខមុនីនាថ នៅលើកទី១ បានបង់ប្រាក់ ចំណែកឯលើកទី២ លើកទី៣ និងលើកទី៤ មិនបង់ប្រាក់ទៅឱ្យដើមបណ្ដឹង គឹម សុខមុនីនាថ ប្រាកដមែន ។

៣- តាមចម្លើយសារភាពដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុគន្ធ បង្ហាញឱ្យឃើញថា៖ ខ្លួនពិតជាបានទិញឥវ៉ាន់ពីដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុខមុនីនាថ និងមិនបានបង់ប្រាក់ឱ្យទៅដើមបណ្ដឹង ប្រាកដមែន ។

៤- តាមអំណានចម្លើយសាក្សីឈ្មោះ [redacted] ធិរាជ បង្ហាញឱ្យឃើញថា៖ ជនជាប់ចោទឈ្មោះ [redacted] អើស ស្នាក់ ពិតជាបានទីញឥវ៉ាន់ចាបហ៊ួយពីដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុខមុនីនាថ ប្រាកដមែន ។

៥- តាមអំណានចម្លើយសាក្សីឈ្មោះ [redacted] ស៊ាងហួ បង្ហាញឱ្យឃើញថា៖ ជនជាប់ចោទឈ្មោះ [redacted] អើសស្នាក់ ពិតជាបានទិញឥវ៉ាន់ ពីដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុខមុនីនាថ ប្រាកដមែន ។

៦- លោកមេធាវី [redacted] បានធ្វើសេចក្តីសន្និដ្ឋានថា៖ តាមចម្លើយជនជាប់ចោទ តាមចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី បង្ហាញឱ្យឃើញថា កូនក្តីរបស់ខ្លួន

ឈ្មោះ [redacted] អើសស្នាក់ ពិតជាបានទិញឥវ៉ាន់ចាប់ហួយពីឈ្មោះ [redacted] សុខមុនីនាថ ប្រាកដមែន ប៉ុន្តែដោយសារតែមានកូនក្តីខ្លួនរកស៊ីខាតទើបធ្វើឱ្យពុំមានលទ្ធភាពក្នុងការសងប្រាក់ទៅឱ្យដើមបណ្តឹងរដ្ឋប្បវេណី ដែលសកម្មភាពនេះមិនមែនបទល្មើសព្រហ្មទណ្ឌឡើយ ស្នើសុំឱ្យតុលការឱ្យកូនក្តីខ្លួនបានរួចផុតពីការចោទប្រកាន់ផង ។

៨- តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា៖ តាមចម្លើយជនជាប់ចោទ អំណានដើមបណ្តឹងរដ្ឋប្បវេណី អំណានចម្លើយសាក្សី ព្រមទាំងភស្តុតាងនានា បង្ហាញឱ្យឃើញថាមានពិរុទ្ធភាពគ្រប់គ្រាន់ក្នុងការចោទប្រកាន់ទៅលើជនជាប់ចោទឈ្មោះ [redacted] អើសស្នាក់ ភេទស្រី ពីបទ: រំលោភលើទំនុកចិត្ត ប្រព្រឹត្តនៅភូមិព្រែកតាកៅ សង្កាត់ដើមមៀន ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីឆ្នាំ២០១៥ តាមបញ្ញត្តិមាត្រា ៣៩១ និងមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ ហេតុដូច្នេះស្នើសុំឱ្យតុលាការធ្វើការផ្តន្ទាទោសលើជនជាប់ចោទតាមកំណត់ច្បាប់។

៩- តាមរបាយការណ៍លេខ ២៣៧ ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៦ របស់ការិយាល័យព្រហ្មទណ្ឌកំរិតស្រាល បង្ហាញឱ្យឃើញថា ជនជាប់ចោទឈ្មោះ [redacted] អើសស្នាក់ ពិតជាបានទៅទិញឥវ៉ាន់ចាប់ហួយពីឈ្មោះ [redacted] សុខមុនីនាថ ចំនួនបីលើក និងមិនសងប្រាក់ទៅឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុខមុនីនាថ ចំនួន ១៤,០៣៥ ដុល្លាអាមេរិក ប្រាកដមែន ។

១០-តាមរបាយការណ៍របស់នគរបាលយុត្តិធម៌ ចម្លើយជនជាប់ចោទ ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី អំណានចម្លើយសាក្សី សេចក្តីសន្និដ្ឋានតំណាងអយ្យការ ព្រមទាំងភស្តុតាងនានា មានភាពស៊ីសង្វាក់គ្នាបង្ហាញឱ្យឃើញថា ជនជាប់ចោទឈ្មោះ [redacted] អើសស្នាក់ បានតែបំបាត់ឥវ៉ាន់ចាប់ហួយ របស់ដើមបណ្តឹងរដ្ឋប្បវេណី និងមិនបានប្រគល់ឥវ៉ាន់ ឬសងប្រាក់ មកអោយដើមបណ្តឹងរដ្ឋប្បវេណីវិញទេ បណ្តាលឱ្យខូចប្រយោជន៍ដល់បណ្តឹងរដ្ឋប្បវេណីប្រាកដមែន ។

១១-អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] អើសស្នាក់ បានធ្វើឱ្យប៉ះពាល់ដល់ទ្រព្យសម្បត្តិឯកជន និងសណ្តាប់ធ្នាប់សាធារណៈ ។

១២-អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] អើសស្នាក់ ដែលបានប្រព្រឹត្តមានធាតុផ្សំគ្រប់គ្រាន់ ជាបទល្មើសព្រហ្មទណ្ឌមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៣៩១ និងមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ ។

១៣-មានភស្តុតាងគ្រប់គ្រាន់បញ្ជាក់អំពីពិរុទ្ធភាពក្នុងការចោទប្រកាន់លើជនជាប់ចោទឈ្មោះ [redacted] អើសស្នាក់ (អត្តសញ្ញាណខាងលើ) ពីបទ: រំលោភលើទំនុកចិត្ត ប្រព្រឹត្តនៅភូមិព្រែកតាកៅ សង្កាត់ដើមមៀន ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីអំឡុងឆ្នាំ២០១៥ តាមបញ្ញត្តិមាត្រា ៣៩១ និងមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ ។

**ខ/ អំពីសំណង និងជម្ងឺចិត្ត**

- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុខមុនីនាថ បានប្តឹងសុំទាមទារប្រាក់ថ្លៃឥវ៉ាន់ចំនួន ១៤,០៣៥ (មួយម៉ឺនបួនពាន់សាមសិបប្រាំ) ដុល្លាអាមេរិក ។ គប្បីតុលាការសម្រេចលើកយកមកពិចារណា ។

**ហេតុដូច្នេះសម្រេច**

១- ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] អើសស្នាក់ (អត្តសញ្ញាណខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល ០៦ (ប្រាំមួយ) ខែ តែទោសនេះត្រូវអនុវត្តព្យួរ ។

ពីបទ: រំលោភលើទំនុកចិត្ត ប្រព្រឹត្តនៅភូមិព្រែកតាកៅ សង្កាត់ដើមមៀន ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីឆ្នាំ២០១៥ តាមបញ្ញត្តិមាត្រា ៣៩១ និងមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ ។



Scanned with CamScanner

២- បង្គាប់ឱ្យជនជាប់ចោទឈ្មោះ [redacted] អើសស្មាក់ សងសំណងទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុខមុនីនាថ ជាទឹកប្រាក់ចំនួន ១៤,០៣៥ (មួយម៉ឺនបួនពាន់សាមសិបប្រាំ) ដុល្លាអាមេរិក ការទាមទារលើសពីនេះត្រូវច្រានចោល ។

សាលក្រមជំនុំជម្រះនៅថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២១ និងប្រកាសជាសាធារណៈនៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២១ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] អើសស្មាក់ ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុខមុនីនាថ ។

ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

**ក្រឡាបញ្ជីសវនាការ**

[redacted]

**ចៅក្រមជំនុំជម្រះ**

[redacted]

បានឃើញ

.......................................

**តំណាងអយ្យការ**

[redacted]

ព្រះរាជអាជ្ញារង

**បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**

ថ្ងៃទី១៥...ខែកក្កដាឆ្នាំ ២០២១..

**ក្រឡាបញ្ជី**

[redacted]